## ទប់ស្កាត់ការសម្លុតធ្វើបាបតាមប្រព័ន្ធអេឡិចត្រូនិច

### បើអ្នកជាកូនសិស្ស. . .

- កុំឆ្លើយឆ្លងតបត ប្រសិនបើមានមនុស្សណាម្នាក់សម្លុតធ្វើបាបអ្នក ឬសម្លុតធ្វើបាបមិត្តភក្តិរបស់អ្នកតាមបណ្តាញប្រព័ន្ធអេឡិចត្រូនិច។ ចូរប្រាប់ឪពុកឬម្តាយរបស់អ្នក, ប្រាប់មនុស្សពេញវ័យណាម្នាក់នៅសាលារៀន, ឬប្រាប់នរណាម្នាក់ដែលអ្នកស.ាល់ទុកចិត្ត។
- ចូរប្រាប់មនុស្សពេញវ័យណាម្នាក់ ប្រសិនបើអ្នកបានទទួលសារលិខិតផ្សេងៗ ដែលធ្វើឲ្យអ្នកមានអារម្មណ៍មិនស្រួលក្នុងចិត្ត, មានខ្លឹមសារអាក្រក់, ឬដែលមានគោលបំណងធ្វើឲ្យរបួសអ្នក ឬនរណាម្នាក់ឈឺចាប់។
- កុំចែកចាយព័ត៌មានណាមួយតាមអ៊ីនធឺណិត ដែលអាចនាំឲ្យអ្នកមានការអាម៉ាស់ឲ្យសោះ។
- កុំចែកចាយព័ត៌មានផ្ទាល់ខ្លួន, ដូចជាឈ្មោះ, អាយុ, អាសយដ្ឋាន, ឬលេខទូរស័ព្ទរបស់អ្នកដល់មនុស្សណាឲ្យសោះ។

### បើអ្នកជាឪពុកឬម្តាយ. . .

- ចូររក្សា ឬផ្តិតសារលិខិត និងរូបថតមិនសមរម្យទាំងប៉ុន្មាន ដែលកូនរបស់អ្នកបានប្រាប់អ្នក ទុក – វត្ថុទាំងនោះគឺជាភស្តុតាង ហើយមានសារប្រយោជន៍ចំពោះវិធានការណាមួយ ដែលអ្នកអាចនឹងអនុវត្តក្នុងពេលអនាគត។
- ចូរទាក់ទងក្រុមហ៊ុនសេវាអ៊ីនធឺណិតរបស់អ្នក ហើយដាក់ពាក្យប្តឹង ប្រសិនបើអ្នកបានទទួលសារលិខិត ឬរូបភាពផ្សេងៗ ដែលអ្នកគិតថា បានល្មើសទៅនឹងវាក្យស័ព្ទ និងល័ក្ខខ័ណ្ឌនានានៃកិច្ចសន្យារបស់អ្នក។
- ចូរទាក់ទងជាមួយសាលារៀន បើសិនជាកូនរបស់អ្នកត្រូវសិស្សណាម្នាក់សម្លុតធ្វើបាប, ឆាឆៅរំខាន, បន្ទាចបំភ័យតាមអ៊ីនធឺណិត។
- បើកូនរបស់អ្នកត្រូវបានចោទប្រកាន់ពីបទសម្លុតធ្វើបាបគេឯងតាមអ៊ីនធឺណិត, ចូរស្វែងរកជំនួយពីក្រុមហ៊ុនអ៊ីនធឺណិតរបស់អ្នក, និងសាលារៀនរបស់អ្នក, ហើយបើមានសេចក្តីបញ្ជាក់ថា ឧប្បត្តិហេតុពិតជាបានកើតឡើងដូចការចោទប្រកាន់មែន, នោះចូរស្វះស្វែងរកការជួយផ្តល់ដំបូន្មានពីអ្នកឯកទេស។
- ចូរទាក់ទងប៉ូលិស បើសិនជាកូនរបស់អ្នកបានទទួលបទល្មើសគំរាមកំហែង ឬរូបថតអាសគ្រាមតាមអ៊ីនធឺណិត។
- ចូរទាក់ទងប៉ូលិស បើសិនជាកូនរបស់អ្នកបានទទួលការហៅតាមទូរស័ព្ទជាពាក្យអាសគ្រាម ឬការផ្ញើសារតាមទូរស័ព្ទជាពាក្យអាសគ្រាម ឬការឆាឆៅរំខានណាមួយ។
- គ្រប់សាលារៀនក្នុងរដ្ឋវ៉ាស៊ីនតោនត្រូវបានតម្រូវដោយច្បាប់ ឲ្យមានបទបញ្ជាផ្ទៃក្នុងទប់ស្កាត់ការសម្លុតធ្វើបាបតាមអ៊ីនធឺណិត – ចូរសិក្សាបទបញ្ជាផ្ទៃក្នុងរបស់សាលារៀនអ្នក ឲ្យបានដិតដល់។
- គួរប្រើប្រាស់កម្មវិធីតម្រងកុំព្យូទ័រ (filters) ដើម្បីជួយបិទខ្ទប់ប្រភេទអត្ថបទនៃផ្សាយមិនសមរម្យនៅតាមបណ្តាញវិបសៃតិ៍នានា។

### ធនធានល្អៗតាមអ៊ីនធឺណិត

- ✓ http://www.netsmartz.org
- ✓ http://www.ncpc.org/cyberbullying
- ✓ http://www.isafe.org
- ✓ http://wiredsafety.org
- ✓ http://www.GetNetWise.org
- ✓ http://safely.yahoo.com
- ✓ http://www.theinternetandyourchild.org

តម្រុយសំរាប់ការប្រើប្រាស់អ៊ីនធឺណិតដោយសុវត្ថិភាព

# សុវត្ថិភាព អ៊ីនធឺណិត



ក្បួនណែនាំសំរាប់ឪពុកម្តាយ
និងកូនជំទង់ៗ

ត្រូវបានរៀបចំឡើងដោយ ៖
Office of Superintendent of Public Instruction
Washington State School Safety Center
http://www.k12.wa.us/SafetyCenter/
Cambodian

# ត្រូវចេះឆ្លាតវៃ

## គន្លឹះសំរាប់ក្មេងជំទង់។

**ការរក្សាសុវត្ថិភាពនៅពេលប្រើប្រាស់អ៊ីនធឺណិត**

អ៊ីនធឺណិតអាចជាឧបករណ៍ស្រាវជ្រាវមួយដ៏ប្រសើរ ហើយក៏ជាមធ្យោបាយមួយក្នុងការរក្សាការទាក់ទងជាមួយបណ្ដាមិត្តភក្តិ និងក្រុមគ្រួសារដ៏ជាទីមនោរមផងដែរ។ ប៉ុន្តែកាប្រើប្រាស់អ៊ីនធឺណិតក៏អាចនាំឲ្យមានគ្រោះថ្នាក់ខ្លះដែរ ដែលអ្នកត្រូវតែដឹងអំពីយុទ្ធវិធីក្នុងការប្រើប្រាស់វា។ នេះគឺជាមធ្យោបាយខ្លះៗ ដែលអ្នកអាចគេចពីគ្រោះថ្នាក់ ក្នុងខណៈដែលអ្នកប្រើប្រាស់អ៊ីនធឺណិត។

### គ្មានអ្វីជាការសម្ងាត់ឡើយ

- ចូរគិតអំពីអ្វីដែលគួរវាយលើកុំព្យូទ័រ។ កុំផ្ញើព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក, ដូចជាឈ្មោះ, អាសយដ្ឋាន, លេខទូរស័ព្ទ, រូបថត, ឬឈ្មោះសាលារៀនរបស់អ្នក ចេញទៅក្នុងលំហរលែកអាកាសអ៊ីនធឺណិតឲ្យសោះ។
- សារអ៊ីមែលអាចត្រូវផ្ញើបន្តចេញទៅក្នុងលំហតែត្រឹមការចុចមួយក្រិកប៉ុណ្ណោះ។ ចូរចាំថា ព័ត៌មានផ្ទាល់ខ្លួនណាមួយដែលអ្នកផ្ញើចេញទៅឲ្យនរណាម្នាក់ នោះគេអាចផ្ញើបន្តទៅឲ្យមនុស្សដទៃទៀត បានយ៉ាងឆាប់រហ័សជាទីបំផុត។

### ត្រូវឆ្លាតវៃ

- កុំឲ្យចេញមុខទៅជួប"មិត្តភក្តិ"ណាម្នាក់ដែលស.ាល់គ្នាតាមអ៊ីនធឺណិត ដោយគ្មានការពិគ្រោះជាមួយឪពុកឬម្ដាយ/អ្នកអាណាព្យាបាលរបស់អ្នកជាមុនឲ្យសោះ។ បើឪពុកឬម្ដាយ/អ្នកអាណាព្យាបាលរបស់អ្នកយល់ព្រម ឲ្យអ្នកទៅជួបគេ, នោះចូរនាំឪពុកឬម្ដាយ/អ្នកអាណាព្យាបាលទៅជាមួយអ្នកផង ហើយចូរដាក់កន្លែងណាត់ជួបគ្នានៅតាមទីសាធារណៈ ដែលគេឯងអាចមើលឃើញងាយ។
- ចូរចាំថា នៅតាមអ៊ីនធឺណិតមនុស្សអាចសម្ដែងការរាក់ទាក់ស្និទ្ធស្នាល ធ្វើដូចជាគេហ្នឹងមានចិត្តល្អ, ប៉ុន្តែនៅក្នុងជីវិតពិត, មនុស្សដ៏ដែលនោះអាចមានសភាពខុសគ្នាទាំងស្រុង។
- ការសម្ដែងអាកប្បកិរិយារបស់អ្នកនៅតាមអ៊ីនធឺណិតគឺជាការទទួលខុសត្រូវរបស់អ្នក។ កុំរំខាន ឬសម្លុតធ្វើបាបមនុស្សណាឲ្យសោះ, ហើយក៏កុំឆ្លើយឆ្លងនឹងមនុស្សណា ដែលចង់បង្កជម្លោះនៅតាមអ៊ីនធឺណិតដែរ។

### ពេលដែលគួរប្រាប់

- បើអ្នកជួបមនុស្សណាម្នាក់ ឬក៏អ្វីមួយនៅតាមអ៊ីនធឺណិត ដែលធ្វើឲ្យអ្នកមានអារម្មណមិនស្រួលក្នុងចិត្ត, ចូរប្រាប់ដល់មនុស្សពេញវ័យណាម្នាក់ ដែលអ្នកស.ាល់ទុកចិត្តជាបន្ទាន់! មនុស្សពេញវ័យអាចពិនិត្យមើលព័ត៌មាននោះនៅលើមុខកុំព្យូទ័រ ហើយអាចសម្រេចថា តើគួររាយការណ៍ ឬមិនគួររាយការណ៍ប្រាប់ភ្នាក់ងារមានសមត្ថកិច្ច។
- "ការអន្ទងទាក់ទងផ្លូវភេទពីអនីតិជន" ("Grooming") គឺជាឱកាសដែលមនុស្សមានវ័យចំណាស់ណាម្នាក់ប្រើអ៊ីនធឺណិត ដើម្បីរកជួបជាមួយពួកយុវជន-នារីក្មេងៗ ដោយមានបំណងបង្កើតនូវទំនាក់ទំនងមិនសមរម្យណាមួយ។
- បើអ្នកសង្ស័យថា រូបអ្នក ឬជនណាម្នាក់ដែលអ្នកស.ាល់ គឺជាចំណុចដៅនៃការអន្ទងទាក់ទងផ្លូវភេទខុសច្បាប់, ចូរប្រាប់មនុស្សពេញវ័យដែលអ្នកស.ាល់ទុកចិត្តជាបន្ទាន់។
- បើអ្នកឃើញអ្វីមួយនៅតាមអ៊ីនធឺណិត មានលក្ខណ:"ល្អហួសការពិត" ("too good to be true"), នោះវាប្រហែលជាមិនពិតទេ។ បើមាននរណាម្នាក់ឲ្យជំនូនអ្វីមួយ ដែលទាមទារឲ្យអ្នកទៅជួបមុខគេដោយផ្ទាល់, គេចាត់ឲ្យនរណាម្នាក់មកជួបអ្នកនៅនឹងផ្ទះ, ឬគេឲ្យអ្នកផ្ញើប្រាក់កាស ឬព័ត៌មាននៃប័ណ្ណឥណទាន (credit card) ទៅឲ្យគេ, នោះចូរប្រាប់ឪពុកឬម្ដាយ ឬអ្នកអាណាព្យាបាលរបស់អ្នក ឲ្យដឹងជាមុន។

# ត្រូវចេះរក្សាសុវត្ថិភាព

## គន្លឹះសំរាប់ឪពុកឬម្ដាយ

**គោលការណ៍ណែនាំផ្នែកសុវត្ថិភាពគ្រួសារសំរាប់ការប្រើប្រាស់អ៊ីនធឺណិត**

ក្នុងចំណោមក្មេងជំទង់ប្រាំនាក់គឺមានម្នាក់ហើយត្រូវគេព្យាយាមអន្ទងផ្លូវភេទតាមអ៊ីនធឺណិតរៀងរាល់ឆ្នាំ។ មានគោលការណ៍ជាក់លាក់មួយចំនួន ដែលអ្នកអាចយកទៅអនុវត្ត ដើម្បីជួយរក្សាសុវត្ថិភាពកូនជំទង់ៗរបស់ផងអ្នក។ ចូរចាប់ផ្ដើមដោយការចូលប្រលូកផ្ទាល់! ចូរអប់រំខ្លួនអ្នក ឲ្យយល់ដឹងអំពីរបៀបដែលអ៊ីនធឺណិតដំណើរការ ហើយចូរឃ្លាំមើលការប្រើប្រាស់ម៉ាស៊ីនកុំព្យូទ័ររបស់កូនអ្នក។

### បង្រៀន

- ចូរបង្កើតផែនការសុវត្ថិភាពអ៊ីនធឺណិតជាលាយលក្ខណ៍អក្សរ។ បង្កើតបទបញ្ជាសំរាប់ការប្រើប្រាស់អ៊ីនធឺណិត និងអ៊ីមែល។ រៀបចំយុទ្ធសាស្ត្រសំរាប់ឲ្យកូនជំទង់ៗរបស់អ្នកប្រើប្រាស់ ដើម្បីទប់ទល់ បើពេលណាពួកគេត្រូវជនណាម្នាក់ព្យាយាមអន្ទងផ្លូវភេទតាមអ៊ីនធឺណិត, ឬបើពេលណាពួកគេជួបប្រទះការភ័យខ្លាច នៅគ្រាឃើញអ្វីមួយតាមអ៊ីនធឺណិត។ ចូរចុះហត្ថលេខានៅលើលិខិតផែនការនោះ, រួចហើយបិទវានៅក្បែរម៉ាស៊ីនកុំព្យូទ័រ។
- ចូររំលឹកប្រាប់កូនជំទង់ៗរបស់អ្នក កុំឲ្យពួកគេប្រាប់ព័ត៌មានផ្ទាល់ខ្លួនដល់ជនណាម្នាក់តាមអ៊ីនធឺណិត។
- ចូរសរសេរចងក្រងជាមួយគ្នានូវបញ្ជីឈ្មោះវត្ថុសំខាន់ៗ ដែលមិនត្រូវបញ្ចេញប្រាប់អ្នកដទៃ, ដូចជាឈ្មោះ, អាយុ, សាលារៀន, លេខទូរស័ព្ទ, អាសយដ្ឋានផ្ទះ, និងរូបថតជាដើម។
- ចូរនិយាយប្រាប់រឿងរ៉ាវផ្សេងៗដល់កូនជំទង់ៗរបស់អ្នក ឲ្យបានញឹកញាប់។ ចូរនិយាយសួរនាំអំពីមិត្តភក្តិ ដែលគេស.ាល់គ្នាតាមអ៊ីនធឺណិត ដូចដែលអ្នកនិយាយសួរនាំអំពីមិត្តភក្តិធម្មតាឯទៀតៗរបស់ពួកគេអញ្ចឹងដែរ។

### ឃ្លាំមើល

- ចូរដាក់ម៉ាស៊ីនកុំព្យូទ័រនៅត្រង់កន្លែងដែលឆាប់មើលឃើញនៅក្នុងផ្ទះ។ ដ្បិតវាធ្វើឲ្យមានការងាយស្រួលក្នុងការឃ្លាំមើលការប្រើប្រាស់កុំព្យូទ័រ។
- ចូរសុំឲ្យកូនជំទង់ៗរបស់អ្នក ជម្រាបប្រាប់អ្នកជាបន្ទាន់អំពីអ្វី ដែលធ្វើឲ្យពួកគេមានអារម្មណ៍មិនស្រួលក្នុងចិត្ត ដោយធានាប្រាប់ពួកគេថា អ្នកនឹងមិនខឹងពួកគេទេ ប្រសិនបើពួកគេប្រាប់រឿងសម្ងាត់ដល់អ្នក។
- គួរប្រើកម្មវិធីសូហ្វវែរតម្រង ឬសូហ្វវែរឃ្លាំមើល។ ចូរចាំថា បើទោះជាឧបករណ៍ទាំងនេះអាចជួយគ្រប់គ្រងការប្រើប្រាស់អ៊ីនធឺណិតរបស់កូនជំទង់ៗរបស់អ្នកក៏ដោយ ក៏វាមិនអាចដើរតួជំនួយការចូលប្រលូក និងការត្រួតពិនិត្យមើលដោយផ្ទាល់របស់ឪពុកម្ដាយបានដែរ។
- ត្រូវដឹងថា កូនជំទង់ៗរបស់អ្នកអាចប្រើប្រាស់កុំព្យូទ័រនៅសាលារៀន, នៅបណ្ណាល័យសាធារណ:, និងនៅផ្ទះរបស់មិត្តភក្តិនានាបានដែរ។

### រាយការណ

- ត្រូវដឹងសញ្ញានៃ"ការអន្ទងទាក់ទងផ្លូវភេទអនីតិជនខុសច្បាប់" ។ ពេលណាមនុស្សវ័យចំណាស់ណាម្នាក់ទាក់ទងជាមួយមនុស្សវ័យក្មេងណាម្នាក់តាមអ៊ីនធឺណិត ដោយមានបំណងបង្កើតនូវទំនាក់ទំនងស្នេហាផ្លូវភេទ, នោះគេហៅថាជា "ការអន្ទងទាក់ទងផ្លូវភេទអនីតិជនខុសច្បាប" ("grooming")។
- បើអ្នកសង្ស័យថា មានគេ "អន្ទងទាក់ទងផ្លូវភេទអនីតិជនខុសច្បាប" តាមអ៊ីនធឺណិតទៅលើរូបកូនជំទង់ ឬកូនណាម្នាក់ផ្សេងទៀតរបស់អ្នក, ចូររាយការណ៍វា ប្រាប់ទីភ្នាក់ងារមានសមត្ថកិច្ចប្រចាំមូលដ្ឋានរបស់អ្នកជាបន្ទាន់។